**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមុខងារសាធារណៈ**
លេខ : ២៦៩៣ មស. ស.ណ

**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

# សេចក្តីជូនដំណឹង
## ស្តីពី
## ការបោះពុម្ពតារាងទូទាត់បៀវត្ស អាណត្តិបើកប្រាក់ និងការបើកផ្តល់បៀវត្ស ជូនមន្ត្រីរាជការសម្រាប់ខែវិច្ឆិកា ឆ្នាំ២០១៥

- យោងសារាចរលេខ០១ សរ ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល
- យោងសារាចរលេខ០២ សរ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សជូននគរបាលជាតិនិងយោធិន
- យោងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ ក្នុងពិធីប្រគល់សញ្ញាបត្រជូននិស្សិតសាកលវិទ្យាល័យវេស្ទើន ។

ក្រសួងមុខងារសាធារណៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានកិត្តិយស សូមគោរពជម្រាបជូនដំណឹង សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័ន ឯកឧត្តម អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត លោក លោកស្រីប្រធានមន្ទីរ និងអង្គភាពជំនាញរាជធានី ខេត្ត មេត្តាជ្រាបថា ក្នុងគោលបំណងចូលរួមអនុវត្តឱ្យបានសម្រេច ស្របតាមសារាចរណែនាំរបស់រាជរដ្ឋាភិបាល ដូចមានក្នុងយោងខាងលើ និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្នុងការជម្រុញការបើកផ្តល់បៀវត្សខែវិច្ឆិកាឱ្យបានឆាប់ ក្រសួងមុខងារសាធារណៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមដាក់ចេញនូវសេចក្តីជូនដំណឹងសម្រាប់អនុវត្ត និងសហការអនុវត្ត ដូចខាងក្រោម៖

- ស្នើសុំក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពជំនាញរាជធានី ខេត្ត ដែលមិនទាន់បានផ្តល់ឯកសារពាក់ព័ន្ធនឹងការប្រែប្រួលស្ថានភាពរដ្ឋបាល និងគ្រួសាររបស់មន្ត្រីរាជការស៊ីវិលសម្រាប់ខែវិច្ឆិកា សូមមេត្តាផ្តល់មកក្រសួងមុខងារសាធារណៈ ឱ្យបានយ៉ាងយូរត្រឹមថ្ងៃទី៣០ **ខែតុលា ឆ្នាំ២០១៥** ដើម្បីក្រសួងមុខងារសាធារណៈមានលទ្ធភាពពិនិត្យនិងបញ្ចូលក្នុងប្រព័ន្ធព័ត៌មានវិទ្យា។ ក្នុងករណីដែលក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពជំនាញ



ផ្លូវវិថីអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

រាជធានី ខេត្ត ផ្តល់ឯកសារមិនទាន់ពេលវេលា ក្រសួងមុខងារសាធារណៈ នឹងធ្វើការបោះពុម្ពតារាងទូទាត់បៀវត្សនិងអាណត្តិបើកប្រាក់បៀវត្សតាម**ខែចាស់** ដោយសន្មតថា ពុំមានការប្រែប្រួលឡើយ

- ក្រសួងមុខងារសាធារណៈនឹងរៀបចំបោះពុម្ពតារាងទូទាត់បៀវត្សនិងអាណត្តិបើកប្រាក់បៀវត្សសម្រាប់ខែវិច្ឆិកាជូនមន្ត្រីរាជការស៊ីវិលឱ្យបានរួចរាល់ក្នុងសប្តាហ៍ទី១នៃខែវិច្ឆិកា
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងធ្វើការត្រួតពិនិត្យនិងរៀបចំបើកផ្តល់បៀវត្សដល់ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពជំនាញរាជធានី ខេត្ត ឱ្យបានទាន់ក្នុងសប្តាហ៍ទី២នៃខែវិច្ឆិកា បន្ទាប់ពីទទួលបានអាណត្តិបើកប្រាក់បៀវត្សពីក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពជំនាញរាជធានី ខេត្ត
- ក្រសួង ស្ថាប័ន សាលារាជធានី ខេត្ត មន្ទីរ និងអង្គភាពជំនាញរាជធានី ខេត្ត ត្រូវធានាការបើកផ្តល់បៀវត្សប្រចាំខែវិច្ឆិកា ឆ្នាំ២០១៥ ជូនមន្ត្រីរាជការស៊ីវិល នគរបាលជាតិ យោធិន ឱ្យបានយ៉ាងយូរក្នុងសប្តាហ៍ទី៣នៃខែវិច្ឆិកា ឆ្នាំ២០១៥ ។

ក្រសួងមុខងារសាធារណៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សង្ឃឹមថា សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័ន ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត លោក លោកស្រីប្រធានមន្ទីរ និងអង្គភាពជំនាញរាជធានី ខេត្ត នឹងចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

រាជធានីភ្នំពេញ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥

| | |
|---|---|
| រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ |
| **អូន ព័ន្ធមុនីរ័ត្ន** | **ពេជ្រ ប៊ុនធិន** |

**ចម្លងជូន៖**

- គ្រប់ក្រសួង ស្ថាប័ន
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- មន្ទីរ និងអង្គភាពជំនាញរាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ